# ដំណើរវិវឌ្ឍមានឆ្ពោះទៅរកការកាត់ទោសលើជនសង្ស័យ ក្នុងសំណុំរឿង០០៣ និង០០៤

ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥

***លីម ជ័យវុត្ថ***
***អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម***
***មជ្ឈមណ្ឌលឯកសារកម្ពុជា***

ក្រោយពីមានការស៊ើបអង្កេតជាផ្លូវការពីសំណាក់សហចៅក្រមស៊ើបអង្កេតអស់រយៈពេលជាច្រើនឆ្នាំ នៅទីបំផុតជនសង្ស័យពីររូបក្នុងចំណោមជនសង្ស័យចំនួន៥រូប ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិលោក ម៉ាក ហាមិន សម្រេចបង្ហាញអត្តសញ្ញាណជាសាធារណៈ និងដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ ទោះបីជាជនទាំងពីររូបនៅពុំទាន់ត្រូវបានចាប់ខ្លួននៅឡើយ ។ ជនត្រូវចោទទាំងពីររូបនោះរួមមាន មាស មុត ជាជនត្រូវចោទក្នុងសំណុំរឿង០០៣ និង អ៊ឹម ចែម ជាជនត្រូវចោទក្នុងសំណុំរឿង០០៤ ។ ចំណែកឯជនសង្ស័យផ្សេងទៀត ពុំទាន់ត្រូវបានសហចៅក្រមអន្តរជាតិបង្ហាញអំពីអត្តសញ្ញាណនៅឡើយ ។

មាស មុត ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខពីបទប្រព្រឹត្តិបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ រីឯ អ៊ឹម ចែម ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ពីបទប្រព្រឹត្តិបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ការដាក់ជនត្រូវចោទទាំងពីររូបឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីបើកផ្លូវឲ្យមេធាវីតំណាងរបស់ជនត្រូវចោទ អាចមានសិទ្ធិចូលពិនិត្យមើលឯកសារក្នុងសំណុំរឿង និងចូលរួមក្នុងកិច្ចនីតិវិធីស៊ើបសួរ ព្រោះចាប់តាំងពីមានការចាត់តាំងមេធាវីតំណាងពីសំណាក់អង្គភាពគាំពារក្តីឲ្យជនសង្ស័យទាំងអស់ដែលមាននៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤រួចមក មេធាវីតំណាងឲ្យជនសង្ស័យទាំងនោះ ពុំត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង និងចូលរួមក្នុងដំណើរការកិច្ចស៊ើបសួរទេ ។ ការផ្តល់សិទ្ធិឲ្យមេធាវីតំណាងរបស់ជនត្រូវចោទអាចចូលពិនិត្យមើលឯកសារក្នុងសំណុំរឿងនាពេលនេះ គឺជាការធានាចំពោះសិទ្ធិទទួលបានការជំនុំជម្រះ

ប្រកបដោយយុត្តិធម៌របស់ជនត្រូវចោទ ឬជនជាប់ចោទ និងដើម្បីលើកស្ទួយប្រសិទ្ធភាពនៃការស៊ើបអង្កេត ។

យោងតាមគម្រោងផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចុះនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ បានរំពឹងថា កិច្ចដំណើរការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង ០០៤ អាចនឹងបិទបញ្ចប់នៅក្នុងត្រីមាសទី១ ឬត្រីមាសទី២ក្នុងឆ្នាំ២០១៥ ហើយដីកាដំណោះស្រាយអាចនឹងចេញនៅត្រឹមត្រីមាសទី៣ ឬទី៤នៃឆ្នាំ២០១៥ ។ នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតអាចនឹងសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬសម្រេចមិនចោទចោទប្រកាន់ អាស្រ័យទៅលើភស្តុតាងដែលទទួលបានពីការស៊ើបអង្កេត ។

ទោះបីជាអត្តសញ្ញាណរបស់ជនសង្ស័យផ្សេងទៀតនៅពុំទាន់ត្រូវបានបង្ហាញយ៉ាងណាក្តី ប៉ុន្តែការសម្រេចបង្ហាញអត្តសញ្ញាណរបស់ជនត្រូវចោទចំនួនពីររូបនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង ០០៤ និងការអនុញ្ញាតឲ្យក្រុមមេធាវីតំណាងរបស់ជនសង្ស័យទាំងពីររូបមានសិទ្ធិចូលមើលឯកសារក្នុងសំណុំរឿង និងចូលរួមកិច្ចស៊ើបអង្កេត ពីសំណាក់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅពេលនេះត្រូវបានមើលឃើញថា ជាដំណើរវិវឌ្ឍឆ្ពោះទៅមុខប្រកបដោយភាពវិជ្ជមាន ដើម្បីនាំយកអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបណ្តាលឲ្យប្រជាជនកម្ពុជារាប់សិបម៉ឺននាក់បាត់បង់ជីវិតមកជំនុំជម្រះទោស និងប្រឈមមុខនឹងយុត្តិធម៌ និងដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះដែលបានទន្ទឹងរង់ចាំអស់រយៈពេលជិត ៤០ឆ្នាំ ។